ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤៦៨ អ.ក
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌ
លេខ ៧៦/"ង១"
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី ចៅក្រុមប្រឹក្សា
លោក ចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៨ អ.ក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] សៅម៉ី ហៅប្រេស៊ីល ភេទប្រុស អាយុ ៣៦ ឆ្នាំ (កើតឆ្នាំ១៩៨៧) ជនជាតិខ្មែរ មុខរបរ កម្មកររោងចក្រ មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សៅមន្នី (រស់) ម្តាយឈ្មោះ [redacted] ចំរើន (រស់) នៅលីវ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារខេត្តកណ្តាល រយៈពេល ៨ ខែ។(ក្នុងឃុំ)

ជាប់ចោទពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ, បទគំរាមកំហែងថានឹងសម្លាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧,មាត្រា ២៣៩ មាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖**

កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១២ និង ៣០ នាទី ថ្ងៃត្រង់ ស្ថិតនៅចំណុចភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ខណៈពេលជនរងគ្រោះឈ្មោះ [redacted] មៅ កំពុងរៀបចំខោអាវចេញពីឃ្លាំងស្រាប់តែឈ្មោះ [redacted] សៅម៉ី ហៅប្រេស៊ីល ដើរមកធ្វើសកម្មភាពចាប់អោប ចាប់ថើប និងចាប់បង្ខំទាញអូសជនរងគ្រោះឈ្មោះ [redacted] មៅ ចូលក្នុងបន្ទប់



Scanned with CamScanner

ដោយប្រើអំពើហិង្សាក្នុងគោលបំណងចាប់រំលោភសេពសន្ថវៈព្រមទាំងបានកាន់កន្រ្តៃគំរាមកំហែងថានឹងសម្លាប់ថែមទៀត ប៉ុន្តែជនរងគ្រោះបានស្រែកវើបំរាស់ ភ្លាមនោះឈ្មោះ [redacted] សៅម៉ី ហៅប្រេស៊ីល បានរត់គេចខ្លួន។ លុះដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងចាប់ឃាត់ខ្លួនឈ្មោះ [redacted] សៅម៉ី ហៅប្រេស៊ីល ព្រមទាំងធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀនជាលទ្ធផលវិជ្ជមាន។

-បានឃើញ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៧៤ ដកសស/២៣ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៩១១ ដកសព/២៣ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ១០១១ ដកដស/២៣ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ១០៨៨ ដកចត/២៣ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

-ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

ឈ្មោះ [redacted] មៅ ភេទស្រី អាយុ ៤៤ ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

-មេធាវី

លោកមេធាវី [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទ។

## នាពេលសវនាការ

១- ជនជាប់ចោទឈ្មោះ [redacted] សៅម៉ី ហៅប្រេស៊ីល ភេទប្រុស បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនបានទៅអោប ចាប់ថើប និងចាប់អូសជនរងគ្រោះចូលក្នុងបន្ទប់បម្រុងចាប់រំលោភ ហើយខ្លួនបានកាន់កន្ត្រៃគំរាមឈ្មោះ ជូន មៅ ពេលនោះជនរងគ្រោះស្រែក ខ្លួនក៏បានទំលាក់កន្ត្រៃ និងបានដើរចេញពីទីនោះ។ ខ្លួនបានប្រើប្រាស់ថ្នាំញៀនដែរ។

២-តំណាងអយ្យការ សួរ ឆ្លើយ ជនជាប់ចោទ៖ ពេលដែលខ្លួនបានចាប់រំលោភជនរងគ្រោះគឺខ្លួនបានប្រើប្រាស់ថ្នាំញៀន។

៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សួរ ឆ្លើយ ជនជាប់ចោទ៖ ខ្លួនពិតជាបាចាប់រំលោភឈ្មោះ [redacted] មៅ ពិតប្រាកដមែន។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានាបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សៅម៉ី ពិតជាបានធ្វើសកម្មភាពប៉ុនប៉ងរំលោភ និងបានគំរាមកំហែងថានឹងសម្លាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] មៅ ភេទស្រី នៅក្នុងផ្ទះរបស់ជនរងគ្រោះដោយជនត្រូវចោទឈ្មោះ [redacted] សៅម៉ី បានចាប់អោប ចាប់ថើប និងបានចាប់បង្ខំទាញអូសជនរងគ្រោះចូលក្នុងបន្ទប់ដោយប្រើអំពើហិង្សាក្នុងគោលបំណងចាប់រំលោភសេពសន្ថវៈ ព្រមទាំងបានកាន់កន្ត្រៃយកមកគំរាមកំហែងថានឹងសម្លាប់ថែម

ទៀតផង ហើយដោយផ្អែកតាមលទ្ធផលតេស្តរកសារធាតុញៀនរបស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថាក្នុងទឹកនោមរបស់ជនជាប់ចោទមានផ្ទុកសារធាតុញៀន ដែលច្បាប់កំណត់អំពើនេះថាជាបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ បទគំរាមកំហែងថានឹងសម្លាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ២៣៣ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់រងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

**ក/ អំពីពិរុទ្ធភាព**

១- តាមដីកាដំណោះស្រាយលេខ ១០១១ ដកដស/២៣ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សៅម៉ី ភេទប្រុស អាយុ ៣៦ ឆ្នាំ (អត្តសញ្ញាណខាងលើ) ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាលបញ្ជូនមកជំនុំជម្រះពីបទៈប៉ុនប៉ងរំលោភសេពសន្ថវៈ បទគំរាមកំហែងថានឹងសម្លាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ២៣៣ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សៅម៉ី បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទពិតជាបានប៉ុនប៉ងចាប់រំលោភ និងបានគំរាមកំហែងថានឹងសម្លាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] មៅ ភេទស្រី អាយុ ៤៤ ឆ្នាំ ប្រព្រឹត្តនៅក្នុងផ្ទះរបស់ជនរងគ្រោះដោយជនជាប់ចោទឈ្មោះ [redacted] សៅម៉ី បានចាប់អោប ចាប់ថើប និងបានចាប់បង្ខំទាញអូសជនរងគ្រោះចូលក្នុងបន្ទប់ដោយប្រើអំពើហិង្សាក្នុងគោលបំណងចាប់រំលោភសេពសន្ថវៈ ព្រមទាំងបានកាន់កន្ត្រៃយកមកគំរាមកំហែងថានឹងសម្លាប់ថែមទៀតផង និងដោយផ្អែកតាមលទ្ធផលតេស្តរកសារធាតុញៀនរបស់មន្ត្រីនគរបាលយុត្តិធម៌ឃើញថាក្នុងទឹកនោមរបស់ជនជាប់ចោទមានផ្ទុកសារធាតុញៀន។

៣- តាមរបាយការណ៍សរុបលេខ ១២៧ របក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកកណ្តាលស្ទឹង បានធ្វើសេចក្តីសន្និដ្ឋានថាជនសង្ស័យឈ្មោះ [redacted] សៅម៉ី ភេទប្រុស អាយុ ៣៦ ឆ្នាំ ពិតជាបានប៉ុនប៉ងរំលោភសេពសន្ថវៈ និងបានគំរាមកំហែងថានឹងសម្លាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] មៅ ។



Scanned with CamScanner

៤- ជនជាប់ចោទឈ្មោះ [redacted] សៅមុី ជានីតិជន មានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ ។

៥- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សៅមុី បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខសណ្តាប់ធ្នាប់ សាធារណៈ របៀបរៀបរយក្នុងសង្គម និងកិត្តិយសអ្នកដទៃ។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សៅមុី នេះមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ២៣៣ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-មានធាតុផ្សំនៃបទល្មើស ដែលមានចែងច្បាស់លាស់ឱ្យផ្តន្ទាទោសតាមមាត្រា២៧ មាត្រា ២៣៣ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-យល់ឃើញថាៈដើមបណ្តឹងរដ្ឋប្បវេណីមិនបានទាមទារសំណងជំងឺចិត្ត និងការខូចខាតពីជនជាប់ចោទនោះទេ តុលាការមិនលើកមកពិចារណាទេ។

០៩-មានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សៅមុី ភេទប្រុស អាយុ ៣៦ ឆ្នាំ (អត្តសញ្ញាណខាងលើ) ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ, គំរាមកំហែងថានឹងសម្លាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះរបស់ជនរងគ្រោះស្ថិតនៅភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ២៣៣ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សៅមុី តាមកំណត់ច្បាប់ ។

**ខ/ អំពីវត្ថុចាប់យក**

កន្ត្រៃចំនួនមួយ

## **ហេតុដូច្នេះសម្រេច**

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សៅមុី (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ ឆ្នាំ។

ពីបទៈ ប៉ុនប៉ងរំលោភសេពសន្ថវៈ, គំរាមកំហែងថានឹងសម្លាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះរបស់ជនរងគ្រោះស្ថិតនៅភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ២៣៣ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-រឹបអូសវត្ថុចាប់យកមានដូចជាកន្ត្រៃចំនួន ១ ទុកជាសម្បត្តិរដ្ឋ។



Scanned with CamScanner

សាលក្រមជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ និងប្រកាសនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | | | |

(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃ ពុធ ០៦ កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពស២៥៦៧

កណ្តាល, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

កណ្តាល, ថ្ងៃទី 01 ខែ 11 ឆ្នាំ២០23

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner